នស/រកម/១២១៥/០១៦

រដ្ឋសភា
ចូល លេខ...
ថ្ងៃទី... ឆ្នាំ២០១... ម៉ោង...
បញ្ជូនទៅ...

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៨/០០១ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា២១ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# វិសោធនកម្មមាត្រា ២១

# នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

**មាត្រាតែមួយ.-**

មាត្រា ២១ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខៈ នស/រកម/០១០៨/០០១ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

**មាត្រា ២១ ថ្មី.-**

ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗ ត្រូវផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង នៃឆ្នាំដែលសមាជិកព្រឹទ្ធសភាបានទទួលខ្ពស់បំផុត ដោយគិតទាំងឋានៈមុខងារផងដែរ កំណត់ស្មើមួយរយភាគរយ ។

ប្រាក់សោធននិវត្តន៍ប្រចាំខែ ត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ ៖

-ពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ ទទួលបានសន្ទស្សន៍ ០,៥%

-លើសពី ៣ ឆ្នាំ ដល់ក្រោម ៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ១%

-ពី ៦ ឆ្នាំ ដល់ក្រោម ១១ ឆ្នាំ ទទួលបានសន្ទស្សន៍ ២%

-ពី ១១ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ៣%

-ពី ១៦ ឆ្នាំ ឡើងទៅ ទទួលបានសន្ទស្សន៍ ៤% ។

អតីតសមាជិកព្រឹទ្ធសភា ទទួលប្រាក់សោធននិវត្តន៍ប្រចាំខែរហូតដល់ទទួលមរណភាព ។

និវត្តជនជាអតីតសមាជិកព្រឹទ្ធសភា នៅពេលជាប់ជាសមាជិកព្រឹទ្ធសភាឡើងវិញ ឬជាតំណាងរាស្ត្រ ឬត្រូវបានតែងតាំង ឬជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបានផ្តល់ប្រាក់សោធននិវត្តន៍ទេ ។ សាមីជនត្រូវបើកប្រាក់បំណាច់ជាសមាជិកព្រឹទ្ធសភា ឬជាតំណាងរាស្ត្រ ឬជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាធម្មតា ហើយនៅពេលចប់អាណត្តិទើបសាមីជនបើកប្រាក់សោធននិវត្តន៍វិញសាជាថ្មី ដោយកែសម្រួលសន្ទស្សន៍ទៅតាមអតីតភាព ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៥

ចរ.ស. ១៥០៦.១១២០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ១១៣៣ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ ឧសភា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**